


ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែមីនា ឆ្នាំ២០១៦ លេខ ៤


## ការចុះសិក្សាប្រមូលព័ត៌មានបឋម ពីវិធានការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសំខាន់ៗនៅបណ្ដាខេត្តគោលដៅ



ក្រោមគម្រោងហិរញ្ញប្បទាន សហប្រតិបត្តិការបច្ចេកទេស “ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍” ក្រសួងបរិស្ថានបានរៀបចំការចុះសិក្សាប្រមូលព័ត៌មានបឋម លើគម្រោងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ របស់ដៃគូអភិវឌ្ឍន៍នានានៅក្នុងខេត្តចំនួន៥ ដោយមានកិច្ចសហការល្អជាមួយក្រសួងពាក់ព័ន្ធថ្នាក់ជាតិ និងមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់។ ការចុះសិក្សានេះគឺ ដើម្បីឈានទៅកំណត់គម្រោងណាដែលជាអាទិភាព ក្នុងការសិក្សាលម្អិតពីលទ្ធភាព សម្រាប់ការរៀបចំសំណើគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍន៍ ទីក្រុងបៃតង ដែលធន់នឹងអាកាសធាតុសម្រាប់ប្រទេសកម្ពុជា ស្វែងរកមូលនិធិពីសហគមន៍ដៃគូអភិវឌ្ឍន៍អន្តរជាតិ។

សកម្មភាពចុះសិក្សាប្រមូលព័ត៌មានបឋមនេះ ត្រូវបានចាប់ផ្ដើមពីថ្ងៃទី២៩ ខែកុម្ភៈ រហូតដល់ទី២៥ ខែមីនា ឆ្នាំ២០១៦ ដែលបានដឹកនាំដោយ ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) ក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ដែលអនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ក្រុមការងារបានសហការយ៉ាងជិតស្និតជាមួយគណៈអភិបាលខេត្តពោធិ៍សាត់ ត្បូងឃ្មុំ ព្រៃវែង បាត់ដំបង និងកំពង់ធំ ព្រមទាំងសមាជិកក្រុមការងារការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលអញ្ជើញមកពីក្រសួង និងមន្ទីរពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសាធារណការ និងដឹកជញ្ជូន។



នៅថ្នាក់មូលដ្ឋាន ក្រុមការងារបានជួបសម្ភាសន៍ជាមួយប្រធានឃុំ ក្រុមប្រឹក្សាឃុំ ប្រជាជន និងអ្នកពាក់ព័ន្ធ ព្រមទាំងពិនិត្យ មើលស្ថានភាពជាក់ស្ដែងពីប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ និងអាងស្តុកទឹក ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀង ការដាំដំណាំឆ្លាស់ ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក និងសហគមន៍ប្រើប្រាស់ទឹកជាដើម។

## លទ្ធផលសំខាន់ដែលត្រូវបានរកឃើញគឺ កង្វះខាតទឹកធ្ងន់ធ្ងរ

កំឡុងពេលចុះសិក្សាស្រាវជ្រាវ ក្រុមការងារបានរកឃើញថាសហគមន៍មួយចំនួនក្នុងខេត្តព្រៃវែង បាត់ដំបង និង ពោធិសាត់ គឺងាយរងគ្រោះនឹងភាពរាំងស្ងួត និងការពន្យាពេលភ្លៀងធ្លាក់មិនទៀងទាត់ ជាហេតុធ្វើឱ្យទឹកសម្រាប់ការធ្វើស្រែចំការមានកម្រិត។ សហគមន៍មួយចំនួនក្នុងខេត្តទាំងនោះ មានប្រឡាយទឹករងប៉ុន្តែមិនមានទឹកគ្រប់គ្រាន់ក្នុងប្រឡាយមេទេ។ ជាទូទៅ ប្រាក់ចំណូលរបស់កសិករបានមកពីប្រភពសំខាន់ចំនួន៣ គឺ ការធ្វើស្រែចំការ ការចិញ្ចឹមសត្វ និងការដាំបន្លែជុំវិញផ្ទះ។ សហគមន៍ ដែលត្រូវបានចុះសិក្សាប្រមូលព័ត៌មាន កសិករប្រើទឹកអណ្តូងសម្រាប់ផលិតកម្មកសិកម្ម និងតម្រូវការទឹកប្រើប្រាស់ក្នុងគ្រួសារ ដោយគ្រួសារកសិករភាគច្រើនមានអណ្តូងយ៉ាងហោចណាស់ចំនួន២។ ការប្រើទឹកអណ្តូងច្រើនពេកបង្កឱ្យមានបញ្ហាដល់គ្រួសារលើការចំណាយប្រេងសាំងដើម្បីបូមទឹក។ ដោយសារមានគ្រួសារច្រើនប្រើយុទ្ធសាស្ត្រដូចៗគ្នា ធ្វើឱ្យកម្រិតបរិមាណទឹកក្រោមដីកាន់តែទាបទៅៗ។ អណ្តូងខ្លះមិនអាចបូមបានទេក្នុងរដូវប្រាំង ដោយសារមានតម្រូវការបូមប្រើប្រាស់ច្រើន។ ការចំណាយលើការបូមទឹក ជាការបន្ថែមលើការចំណាយផលិតកម្ម ហើយកសិករកំពុងជួបការលំបាកលើបញ្ហានេះ។



ធនធានទឹកកាន់តែមានភាពប្រឈមដែលរាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរណែនាំស្តីពីការចាត់វិធានការថែរក្សាទឹកទុក(ផ្សព្វផ្សាយថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥) ដល់កសិករសម្រាប់ការងារបង្កបង្កើនផលស្រូវប្រាំងក្នុងរដូវនេះ គឺអាចធ្វើបានតែមួយដងប៉ុណ្ណោះ។ ទឹកដែលមានបន្ទាប់ពីធ្វើការដាំដុះរួចគួរត្រូវបានរក្សាទុកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃនិងដំណាំចម្រុះ។ សារាចរណែនាំត្រូវបានផ្សព្វផ្សាយបន្ទាប់ពីក្រសួងធនធានទឹក និងឧតុនិយមបានព្យាករណ៍ថា កម្ពុជានឹងទទួលរងនូវបាតុភូតពីខែកុម្ភៈដល់ចុះខែមិថុនាឆ្នាំ២០១៦ អាចនឹងបង្កឱ្យរដូវវស្សាមកដល់យឺត និងមានភ្លៀងធ្លាក់តិចក្នុងឆ្នាំនេះ។ សីតុណ្ហភាពក្តៅហួតហែងគឺត្រូវបានរំពឹងថានឹងបង្កើនគ្រោះរាំងស្ងួត។ ជាលទ្ធផល កម្ពុជាប្រឈមនឹងការខ្វះខាតទឹកហូតដល់ពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៦។ ប្រសិនបើមានបាតុភូតថ្មី (La Nina) កម្ពុជានឹងមានភ្លៀងចាប់ផ្តើមធ្លាក់ច្រើនជាងធម្មតា។

កសិករបានសម្របនឹងស្ថានភាពរាំងស្ងួតដោយផ្លាស់ប្តូរការធ្វើស្រែពីស្ទូងទៅជាព្រួស ជីកស្រះ រក្សាទឹកភ្លៀងទុក និងបច្ចេកទេសរក្សាទឹកទុក។ ប៉ុន្តែយើងចាំបាច់ត្រូវមានគោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងទឹកក្រោមដីមុនការខូចខាតកាន់តែធ្ងន់ធ្ងរពីការបូមទឹកក្រោមដីយកមកប្រើប្រាស់ជាអចិន្ត្រៃយ៍ដែលគ្មានការគ្រប់គ្រងត្រឹមត្រូវ។ ការចុះសិក្សាប្រមូលព័ត៌មានបឋមបានឱ្យឃើញពីតម្រូវការវិនិយោគបន្ថែមលើយន្តការ ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងទឹកក្រោមដីសម្រាប់សហគមន៍នៅគ្រប់រដូវ។ វិធានការបែបនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំសំណើបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលនឹងរៀបចំដោយគម្រោង ដោយយោងតាមការវាយតម្លៃកំឡុងពេលចុះសិក្សាប្រមូលព័ត៌មានបឋម និង ការសិក្សាលម្អិតពីលទ្ធភាពសម្រាប់ការរៀបចំសំណើគម្រោងបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុនាចុងឆ្នាំនេះ។



## ការអនុវត្តនូវការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងការផ្តួចផ្តើមដទៃទៀតជាច្រើនត្រូវបានសិក្សាស្រាវជ្រាវ តាក់តែងរៀបចំនិងចែករំលែកពីការអនុវត្តដើម្បីឱ្យការវិនិយោគការអភិវឌ្ឍប្រទេសកាន់តែ ធន់នឹងអាកាសធាតុ។ ដើម្បីសម្រេចបានជោគជ័យសម្រាប់បច្ចុប្បន្ន និង តទៅថ្ងៃអនាគតក្នុងការចូលរួមពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចក្នុងសង្គម បរិស្ថាន និងវប្បធម៌ ការអនុវត្តជាច្រើនកើតចេញពីសកម្មភាពរបស់បុគ្គល និងសហគមន៍ដែលស្វះស្វែងរកមធ្យោបាយ និងចាត់វិធានការដើម្បីបន្ស៊ាំនឹងស្ថានភាពដែលប្រែប្រួល។ ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុក្នុង



ការអនុវត្ត គឺជាព័ត៌មានចំណេះដឹងរបស់គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ដើម្បីចែករំលែកព័ត៌មានទាំងនេះជាបន្តបន្ទាប់ដល់អ្នកពាក់ព័ន្ធ។



គម្រោងអភិវឌ្ឍន៍កសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ចត្រូវបានកំពុងអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងកិច្ចសហការជាមួយអង្គការអោយឌីអី និងអ្នកពាក់ព័ន្ធផ្សេងៗនៅខេត្តព្រៃវែងចាប់តាំងពីឆ្នាំ២០១២។ ការផ្តួចផ្តើមនេះ ជាការគាំទ្រដល់កសិករដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគាត់ដែលអាចរកបានពីសកម្មភាពនានាក្នុងកសិដ្ឋានដោយសន្សំសំចៃការប្រើប្រាស់ទឹកតិច ជាពិសេសនៅដើមឆ្នាំនេះដោយសារមានបាតុភូត (El Nino) ធ្វើឱ្យសីតុណ្ហភាពកម្តៅកើនឡើង។ នៅឃុំព្រែកកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង កសិករចាប់ផ្តើមនាំគ្នាដាំឪឡឹកពីខែមករា ដល់ខែកុម្ភៈ។

ទោះបីកសិករធ្វើស្រែជាប្រពៃណី ពួកគាត់បានកត់សម្គាល់ថាការដាំឪឡឹកត្រូវការប្រើប្រាស់ទឹកតិចជាងការធ្វើស្រែ និងអាចឱ្យរកប្រាក់ចំណូលបានច្រើនជាង។ ការដាំឪឡឹក ត្រូវការកំលាំងពលកម្មច្រើន ដែលជាភាពប្រឈមដល់តំបន់ជនបទដែលសមាជិកគ្រួសារស្ថិតក្នុងវ័យកណ្តាលនាំគ្នាចាកចេញទៅធ្វើការនៅឯទីក្រុង។ ប៉ុន្តែកសិករដែលមានប្រាក់ចំណូលបន្ថែម កំពុងសម្របខ្លួនដោយជួលកំលាំងពលកម្មបន្ថែមពេលណាដែលត្រូវការចាំបាច់។ ជារួម កសិករមានលទ្ធភាពបង្កើនប្រាក់ចំណូល បើទោះបីជាត្រូវបន្ថែមការចំណាយលើផលិតកម្មក៏ដោយ។ ជាឧទាហរណ៍មួយទៀតគឺការចិញ្ចឹមមាន់។ លោកស្រី យ៉យ ធី អាយុ៣៤ឆ្នាំនៅភូមិព្រៃឃ្នាស ស្រុកមេសាង ខេត្តព្រៃវែង បានចាប់អារម្មណ៍ក្នុងការចិញ្ចឹមមាន់ដើម្បីរកប្រាក់ចំណូលដោយសារការចិញ្ចឹមមាន់មិនត្រូវការទឹកច្រើន។ តាមរយៈការចិញ្ចឹមមាន់ គាត់ក៏អាចធ្វើការងារផ្សេងៗទៀតនៅជុំវិញផ្ទះបាន។ បន្ទាប់ពីគាត់ចូលរួមការបណ្តុះបណ្តាលពីការចិញ្ចឹមមាន់កាលពីឆ្នាំ២០១២ លោកស្រី យ៉យ ធី និងអ្នកភូមិដទៃទៀត បានបង្កើនការចិញ្ចឹមមាន់ដែលអាចរកប្រាក់ចំណូលបានពី៤០.០០០ ដល់៥០.០០០រៀល ក្នុងមួយថ្ងៃ។

កសិករនៅក្នុងតំបន់នេះ ពិសេសក្រុមស្រ្តី កំពុងសម្របការរស់នៅរបស់ពួកគាត់ទៅនឹងកង្វះទឹកតាមរយៈការប្រើប្រាស់ប្រព័ន្ធដំណក់ទឹកសម្រាប់ផលិតកម្មកសិកម្មរបស់ពួកគាត់។ ដោយសារគ្មានទឹកគ្រប់គ្រាន់ក្នុងប្រឡាយនៅរដូវប្រាំង កសិករ ធន សឿន ចាប់ផ្តើមបូមទឹកពីអណ្តូង និងស្រះដែលបានជីកដើម្បីស្រោចស្រពដំណាំគាត់ដោយប្រើប្រាស់ប្រព័ន្ធដំណក់ទឹកដែលជួយបន្ធូរបន្ថយពេលវេលានិងកំលាំងពលកម្ម។ កសិករភាគច្រើនដាំបន្លែនៅផ្ទះសម្រាប់បរិភោគ និងលក់ដូរនៅផ្សារក្នុងសហគមន៍ និងកសិករមួយចំនួនបានចែកចាយបន្លែអត់ជាតិគីមីរបស់ពួកគាត់មកទីផ្សារនៅភ្នំពេញ ក៏ដូចជាតាមទីផ្សារទំនើបនានា។ ពួកគាត់អាចរកចំណូលបានប្រហែលចំនួន២០.០០០រៀលក្នុងមួយថ្ងៃ។កសិករមួយចំនួនក៏ដាំបន្លែក្នុងវាលស្រែរបស់ពួកគាត់ផងដែរ បន្ទាប់ពីច្រូតស្រូវរួច។

## យន្តការអង្គការសង្គមស៊ីវិលសម្រាប់ភាពធន់អាកាសធាតុ

តាមរយៈយន្តការអង្គការសង្គមស៊ីវិល លើការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍នៃជំនួយបច្ចេកទេស (TA-8179) ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ (PPCR) ក្រសួងបរិស្ថាន និង អង្គការភ្លែនអន្តរជាតិកំពុងផ្តល់ហិរញ្ញប្បទានខ្នាតតូចដល់អង្គការសង្គមស៊ីវិលនៅកម្ពុជា ដើម្បីអនុវត្តគម្រោងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបញ្ជ្រាបទស្សនទាននៃការបន្សាំ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការងារប្រតិបត្តិរបស់ខ្លួន។ ហិរញ្ញប្បទានខ្នាតតូចគឺចន្លោះពី ៤០.០០០ ដល់ ១០០.០០០ ដុល្លាសហរដ្ឋអាមេរិក នឹងផ្តល់ឲ្យទៅអង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ និងអនុវត្តការបន្សាំនឹងការប្រែប្រួលអាកាសធាតុឈ្នះគម្រោងដោយមានរយៈពេល ១៨ខែក្នុងការអនុវត្តគម្រោង។

ចាប់ផ្តើមតាំងពីចុងខែសីហា ឆ្នាំ២០១៥ អង្គការមិនមែនរដ្ឋាភិបាលនៃសង្គមស៊ីវិលចំនួន ១៣៦ បានចាប់អារម្មណ៍នឹងគម្រោងដោយបានដាក់សំណើ។ បន្ទាប់ពីបានធ្វើការពិនិត្យ និងជ្រើសរើសយ៉ាងល្អិតល្អន់នោះ អង្គភាពចំនួន១៩ ត្រូវបានសំរាំងជ្រើសរើសក្នុងការសម្រេចចិត្តជាចុងក្រោយ ហើយ នឹងត្រូវបញ្ជូនទៅក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ីចុងខែមេសានេះសម្រាប់ការអនុម័តផ្តល់ហិរញ្ញប្បទាន។ មូលនិធិដែលផ្តល់ឱ្យអង្គការសង្គមស៊ីវិលទាំង១៩នេះនឹងយកទៅប្រើប្រាស់យ៉ាងទូលំទូលាយលើ បទអន្តរាគមន៍ផ្សេងៗតាមនិតិវិធីនិងបែបបទរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការ យ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងប្រជាជន និងអ្នកពាក់ព័ន្ធ ដូចជាវិស័យកសិកម្ម ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹក (ទឹកស្អាត) ហេដ្ឋារចនាសម្ព័ន្ធទីក្រុង សុខភាពនិងអនាម័យ ការគ្រប់គ្រងធន ធានធម្មជាតិ ការអប់រំគាំទ្រលើសកម្មភាពចិញ្ចឹមជីវិត ការបង្កើនប្រាក់ចំណូល ការបញ្ជ្រាបចូលទៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ

ហានិភ័យគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ជាដើម។ ស្ថាប័នដៃគូមួយចំនួន នឹងធ្វើការដោយសង្កត់ធ្ងន់លើក្រុមងាយរងគ្រោះ ដូចជាក្រុមស្ត្រី ក្រុមយុវជន ជនពិការនិងកុមារ ព្រមទាំងជនជាតិដើមភាគតិច និងប្រជាពលរដ្ឋក្រីក្រនៅជាយក្រុងផងដែរ។ គម្រោងអង្គមស៊ីវិល នឹងអនុវត្តនៅ១៧ខេត្តក្រុងទូទាំងប្រទេសកម្ពុជា ដូចមានក្នុងផែនទីខាងក្រោម៖




ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ អង្គការផ្លែនអន្តរជាតិ តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងបរិស្ថាន បានរៀបចំវគ្គបណ្តុះបណ្តាលមួយអំពីការគ្រប់គ្រងគម្រោងការបន្សាំនឹងការប្រែប្រួលអាកាសធាតុសហគមន៍ ដែលធ្វើនៅខេត្តកំពង់ធំក្នុងគោលបំណង៖

- ផ្តល់បរិបទទូទៅដល់គម្រោង ដើម្បីធ្វើការឱ្យមានភាពស៊ីគ្នាជាមួយផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងគោលនយោបាយនានារបស់ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី។
- ផ្តល់បច្ចេកទេស ជំនាញ និងឧបករណ៍ជាក់ស្តែង ដល់អង្គការសង្គមស៊ីវិលដៃគូ ដើម្បីអនុវត្តគម្រោងឱ្យបានជោគជ័យ និងអនុលោមតាមធនាគារអភិវឌ្ឍន៍អាស៊ី អង្គការផ្លែនអន្តរជាតិ និងបទដ្ឋានជាក់លាក់នៃគម្រោង (ការរៀបចំកិច្ចសន្យា ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ បទបញ្ញត្តិហិរញ្ញវត្ថុ របាយការណ៍ និងឯកសារចំណេះដឹង)។
- ការពង្រឹងឡើងវិញ និងបន្ថែមទៅលើផ្នែកអន្តរវិស័យ និងមានភាពប្រទាក់ក្រឡាគ្នា ដែលបានជ្រើសរើសពីការបណ្តុះបណ្តាលលើកទី១ (គ្រប់គ្រងទឹក រួមបញ្ចូលគ្នានឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបញ្ជ្រាបការបន្សាំទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ថាមពលកកើតឡើងវិញ ផ្នែកយេនឌ័រ យុវជន និងការប្រែប្រួលអាកាសធាតុ ។ល។)

គម្រោងទាំងអស់ ធ្វើយ៉ាងណាឲ្យមានទំនាក់ទំនងគ្នា និងកិច្ចសហការរវាងស្ថាប័នដៃគូ ជាមួយកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុដែលធ្វើការពាក់ព័ន្ធក្នុងវិស័យកសិកម្ម ការគ្រប់គ្រងទឹក ជីវចម្រុះ ការអភិរក្សធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន។ គម្រោងដែលទទួលហិរញ្ញប្បទានខ្នាតតូចទាំងនេះនឹងជួយជម្រុញ និងផ្តល់ព័ត៌មានជាមូលដ្ឋាន នៃការរៀបចំគោលនយោបាយរបស់រដ្ឋាភិបាលលើការដោះស្រាយភាពប្រឈមនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយព្រមទាំងការអនុវត្តបច្ចេកទេសមួយចំនួន ការជ្រើសរើស និងអនុវត្តម៉ូដែលសមស្រប ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ និងផ្សព្វផ្សាយចែករំលែកដល់គម្រោងក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ។

ការជួបប្រជុំជាមួយអង្គការសង្គមស៊ីវិលទាំង១៩និងសមាជិកគណៈកម្មាការសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាស នឹងរៀបចំឡើងនៅចុងខែមេសា ឆ្នាំ២០១៦ខាងមុខនេះ។




សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងគម្រោង ឬចំណាប់អារម្មណ៍លើការសហប្រតិបត្តិការនេះ សូមទាក់ទងមក អ្នកស្រី ហ្សន់ អេវើរីត ដែលជាប្រធានក្រុមការងារបច្ចេកទេស ឬ

លោកយុន ស៊ីណា អ្នកឯកទេសផ្នែកកសាងសមត្ថភាព និងបណ្តុះបណ្តាល ។

១. ហ្សន់ អេវើរីត ៖ everett.jeanne@plan-international.org
២. យុន ស៊ីណា sina.yun@plan-international.org



*ការបើកវគ្គបណ្តុះបណ្តាលសម្រាប់អង្គការសង្គមស៊ីវិលជាលើកទី២ នៅខេត្តកំពង់ធំ*

## សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ



ថ្ងៃច័ន្ទ ទី០៤ ខែមេសា ឆ្នាំ២០១៦ ៖ ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធបានមកពីក្រសួងស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាចូលរួម “សិក្ខាសាលាបណ្តុះបណ្តាលស្តីពី ឧបករណ៍ជ្រើសរើស ហានិភ័យអាកាសធាតុ” នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ក្រោមការដឹកនាំដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ ឯកឧត្តមប៉ុន សារឿន និងឯកឧត្តមវ៉ាន់ មុនីនាថ។ សិក្ខាសាលានេះ បានរៀបចំដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន ក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី“ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍”។

អង្គសិក្ខាសាលា បានកំណត់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ ដែលសមស្របបំផុតសម្រាប់វិស័យធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ គោលបំណងនៃសិក្ខាសាលាបណ្តុះបណ្តាលគឺ៖

១. ពិនិត្យមើលលើឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា និងប្រទេសនានា
២. ពិភាក្សា និងវិនិច្ឆ័យបញ្ជីជ្រើសរើសក្នុងវិស័យសំខាន់ចំនួន៣៖ ធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ
៣. កសាង និងកំណត់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុដែលសមស្របតាមវិស័យធនធានទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

ឧបករណ៍ជ្រើសរើសទាំងនេះ គឺជាលទ្ធផលមួយក្នុងសូចនាករនានាដែលបានកំណត់ និងជាមធ្យោបាយសំខាន់ណាស់ដើម្បីប្រើប្រាស់ក្នុងការវាយតម្លៃគម្រោងវិនិយោគ និងបំពេញបន្ថែមលើឧបករណ៍ជ្រើសរើសសង្គម និងបរិស្ថានជាទូទៅដែលកំពុងត្រូវបានប្រើប្រាស់ដោយក្រសួងបរិស្ថាន។ ប្រធានបទក៏ផ្តោតទៅលើចំណេះដឹងដែលត្រូវការចាំបាច់សម្រាប់ការប្រើប្រាស់ឧបករណ៍ឱ្យជោគជ័យដោយដកស្រង់ចេញពីគម្រោងផ្សេងៗ ដែលកំពុងអនុវត្តដោយក្រសួងគោលដៅសំខាន់ៗ (ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ) នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ដែលគាំទ្រថវិកាពីមូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។

# សូមជម្រាបជូនពីការរៀបចំតាក់តែងរចនាគេហទំព័រជាថ្មីរបស់កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា

គេហទំព័រកម្មវិធី www.spcrcambodia.org ត្រូវបានរៀបចំតាក់តែងរចនាជាថ្មីដោយផ្សព្វផ្សាយព័ត៌មាន និងឯកសារចំណេះដឹងបច្ចុប្បន្នភាព ដែលបានចងក្រងពាក់ព័ន្ធនឹងសកម្មភាពការងារនៃភាពធន់នឹងអាកាសធាតុនៅកម្ពុជា។ ព័ត៌មាន និងឯកសារថ្មីៗដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុរួមមាន៖

- ទំព័រអំពីគម្រោងវិនិយោគនីមួយៗ ទាំង៧របស់កម្មវិធី SPCR គឺគម្រោងភាពធន់នឹងអាកាសធាតុផ្លូវជនបទ http://www.spcrcambodia.org/cpr.php
- គម្រោងភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ http://www.spcrcambodia.org/cpi.php
- គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ http://www.spcrcambodia.org/frid.php
- គម្រោងលើកស្ទួយកសិកម្មធន់នឹងអាកាសធាតុ http://www.spcrcambodia.org/promotingclimate.php
- គម្រោងភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការបន្សុំាផ្តោតលើមុខជំនួញ http://www.spcrcambodia.org/promotingclimate.php
- គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធន់នឹងទឹកជំនន់ http://www.spcrcambodia.org/promotingclimate.php
- គម្រោងភាពធន់នឹងអាកាសធាតុនៃផ្លូវជនបទ http://www.spcrcambodia.org/promotingclimate.php
- ព្រឹត្តិការណ៍សកម្មភាពថ្មីៗ--សកម្មភាពកម្មវិធីSPCRដែលគ្រោងនឹងអនុវត្តនាពេលខាងមុខ
- ឯកសារបោះពុម្ពថ្មីៗ--ទាញយកឯកសារថ្មីពាក់ព័ន្ធនឹងភាពធន់នឹងអាកាសធាតុនៅកម្ពុជា
- មានទំព័រជាច្រើនទៀត...ភ្ជាប់ទៅទំព័រ Facebook របស់កម្មវិធី SPCR និងសូមមេត្តាផ្តល់ព័ត៌មានមកក្រុមការងារយើងខ្ញុំពីសំណូមពររបស់អស់លោកអ្នក តាមរយៈ https://www.facebook.com/spcrcambodia/




## សម្រាប់ព័ត៌មានបន្ថែម៖


ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ ប្រធានសម្របសម្រួលកម្មវិធី

លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

អគារមរតកតេជោ ឡូតិ៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ៥៥ ២៣ ៥៣១៤ ៧៧៧ អ៊ីម៉ែល៖ adbspcrta8179@gmail.com